00776997

E169

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង**

កាលបរិច្ឆេទ: ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២

**ជូនចំពោះ:** **ការិយាល័យសហព្រះរាជអាជ្ញា**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង,មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង និងភាគីនៃសំណុំរឿង ០០២**

**កម្មវត្ថុ:** **សំណើសុំព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបដែលអ្នកជំនាញ** TCE-33 **បានរៀបចំ**

ក្នុងអំឡុងសវនាការកាលពីថ្ងៃទី ១៧ និងថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២ កន្លងមក យើងបានដឹងថាឯកសារមួយចំនួន ដែលក្នុងនោះរួមមានទាំងទស្សនាវដ្តីយុវជនបដិវត្តន៍ និងទស្សនាវដ្តីទង់បដិវត្តន៍ផងដែរតាមពិតគឺជាសេចក្តីសង្ខេបដែលបានរៀបចំឡើងដោយអ្នកជំនាញ ដែលមានរហស្សនាម TCE-33 (រហស្សនាម P-037 នៅក្នុងបញ្ជីឈ្មោះអ្នកជំនាញរបស់សហព្រះរាជអាជ្ញា, ឯកសារ E9/4.2) (ប្រតិចារឹក ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១១៣, ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៣-៤ (មានជាភាសាបារាំងតែប៉ុណ្ណោះ) និង ទំព័រ ១៧)។

ដោយអនុលោមតាមវិធាន៩៣ នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្ញើសំណើជាលាយលក្ខណ៍អក្សរមួយច្បាប់ទៅអ្នកជំនាញខាងលើ ដើម្បីស្នើសុំឲ្យគាត់ផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសេចក្តីសង្ខេបទាំងអស់នេះមកអង្គជំនុំជម្រះ។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 09 / 02 / 2012
ម៉ោង (Time/Heure) : 10:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: [illegible]

00776998

E169

អង្គជំនុំជម្រះសាលាដំបូងស្នើឱ្យសហព្រះរាជអាជ្ញាផ្តល់ឯកសារយោងសម្រាប់ឯកសារទាំងនេះ និង បញ្ជាក់ថាតើមានសេចក្តីសង្ខេបប្រភេទនេះផ្សេងទៀតដែរ ឬយ៉ាងណា ដែលបានរៀបចំដោយអ្នកជំនាញខាងលើនៅក្នុងសំណុំរឿង និងឯកសារយោងសម្រាប់រៀបចំឯកសារសង្ខេបទាំងនោះ។ អង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាដាក់ព័ត៌មាននេះ ទៅក្នុងសំណុំរឿងឱ្យបានត្រឹមថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងដាក់បញ្ចូលព័ត៌មានទាំងនេះទៅក្នុងសំណើសុំព័ត៌មានរបស់ខ្លួនពីអ្នកជំនាញ ដែលមានរហស្សនាម TCE-33 នេះ។

សំណើនេះកើតចេញពីការពិភាក្សានៅក្នុងតុលាការ ពាក់ព័ន្ធនឹងសេចក្តីសង្ខេប ហើយពុំមែនជាសេចក្តីសម្រេចស្តាប់សក្ខីកម្មអ្នកជំនាញរូបនេះឡើយ។ នាពេលបច្ចុប្បន្ន សេចក្តីសម្រេចស្តាប់សក្ខីកម្មរបស់អ្នកជំនាញខាងលើកំពុងស្ថិតក្រោមការពិចារណា។